**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# របាយការណ៍
## ស្តីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែតុលា ឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែតុលា ឆ្នាំ២០១៤នេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានបញ្ចប់ជាស្ថាពរហើយ បើប្រៀបធៀបរយៈពេលដូចគ្នាគឺតិចជាងឆ្នាំមុន៥.១៩១ហិកតា។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន២.៥៥៧.៥៧៣ហិកតា ស្មើនឹង១០៦,០៧ភាគរយ នៃផែនការ២.៤១១.២០៧ហិកតា។ រីឯការខូចខាតដំណាំស្រូវដោយគ្រោះធម្មជាតិមកទល់ពេលនេះអាចវាយតម្លៃជារួមប្រមាណ៤១.៥១៤ហិកតា ស្មើនឹង១,៦២ភាគរយនៃផ្ទៃដីអនុវត្តបាន២.៥៥៧.៥៧៣ហិកតា ដែលក្នុងនោះមានខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ បាត់ដំបង សៀមរាប កំពង់ធំ ពោធិ៍សាត់ និងខេត្តព្រៃវែង អនុវត្តបានច្រើនជាងគេនិងមានខេត្តមួយចំនួនបានបញ្ចប់ការដាំដុះដោយទទួលបានលើសផែនការ។ ដោយឡែកនៅខេត្តតាកែវ កំពត កំពង់ឆ្នាំង និងខេត្តកំពង់ចាម ត្រូវបានពន្យារពេលការដាំដុះស្រូវរដូវវស្សាដោយសារគ្រោះរាំងស្ងួតបានអូសបន្លាយចាប់ពីចុងខែកក្កដា រហូតដល់ចុងខែកញ្ញា ប៉ុន្តែខេត្តកំពង់ស្ពឺនៅតែបន្តការដាំដុះ។ ទន្ទឹមនេះដែរនៅមូលដ្ឋានខ្លះនៃខេត្តកំពង់ស្ពឺ កំពត និងកំពង់ឆ្នាំង កំពុងជួបប្រទះកង្វះទឹកជាបណ្តើរៗ ហើយដែលអាចនឹងបណ្តាលឲ្យទិន្នផលធ្លាក់ចុះជាយថាហេតុ។

ក្រសួងក៏បានណែនាំដល់អង្គភាពជំនាញក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្ត បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវ និងយកចិត្តទុកដាក់លើការគ្រប់គ្រងនិងប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ក៏ដូចជាការពារទឹកទុកឲ្យបានគត់មត់នៅចុងរដូវវស្សាសម្រាប់បង្កបង្កើនផលដំណាំស្រូវរដូវប្រាំងនៅពេលខាងមុខនេះ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០១៤ នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

- ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៩៧៥.១២១ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៧១១.៣៦៤ហិកតា ស្មើនឹង២៣,៩១% និងគ្រឿងយន្តចំនួន២.២៦៣.៧៥៧ហិកតា ស្មើនឹង៧៦,០៩%) តិចជាងឆ្នាំមុនចំនួន២៧៤.០៩៤ហិកតា
- ផ្ទៃដីសាបសរុបចំនួន១១៣.៣៣២ហិកតា តិចជាងឆ្នាំមុនចំនួន៤៥.៥៥៤ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន២.៥៥៧.៥៧៣ហិកតា ស្មើនឹង១០៦,០៧ភាគរយនៃផែនការ២.៤១១.២០៧ហិកតា តិចជាងឆ្នាំមុនចំនួន៥.១៩១ហិកតា រួមមាន៖
    - ស្រូវស្រាលចំនួន៦៦១.២៨៥ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៧៧.៤៤៦ហិកតា) លើសឆ្នាំមុនចំនួន១.៧៩៨ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh. Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

| | | | | | |
|---|---|---|---|---|---|
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.០៣៨,០០ | ៣.៤៦៩,៧៩ | ១.២៤៨,៥០ | ១.១២៨,៨០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៤៧,៩២ | ៣.៧៥៣,២១ | ៣.៣១៣,៤០ |
| សរុប II | | ២៦.៩៦៤,០៤ | ២៦.៩៣៦,៨៩ | ២៧.៤១៣,២៨ | ២០.០៤៤,៥២ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | - | - |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៨៤.៩០២,០០ | ៤១.៤៩១,០០ | ៤១.៤៩១,០០ |
| សរុប III | | ៦១.២៧១,០០ | ២២០.៣៤៨,០០ | ៤១.៤៩១,០០ | ៤១.៤៩១,០០ |
| សរុប I+II+III | | ៨៨.៦៤១,៦៤ | ២៤៧.៦២៩,២០ | ៦៩.៣៧៤,១៥ | ៦១.៩៣៥,៥២ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ធ្វើតេស្តសំណាកយថាប្រភេទចំនួន២១សំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង
- រៀបចំទីតាំងបង្កើតច្បារពូជថ្មីនៅប្លុក២១ និងដាក់ស្លាកសញ្ញាសម្គាល់លើកូនកៅស៊ូតាមកូននីមួយៗសម្រាប់ដាំក្នុងច្បារពូជ
- កាប់ព្រៃតាមចន្លោះរងក្នុងឡូត៍នីមួយៗ លាបថ្នាំរញោចនិងលាបខ្លាញ់គោ ព្រមទាំងបាញ់ថ្នាំការពារជំងឺកូនកៅស៊ូ និងដាក់ជីលើកូនកៅស៊ូតាមចង់
- ដឹកនាំនិស្សិតសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យ

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

-ជ្រូកសរុបចំនួន៣៦៣ក្បាល នៅក្នុងស្ថានីយ៍ពិសោធន៍ពូជជ្រូក ក្នុងនោះៈជ្រូកបាចំនួន១២ក្បាល ជ្រូកមេចំនួន១០១ក្បាល និងកូនជ្រូកចំនួន២៥០ក្បាល

-គោសរុបចំនួន១៥១ក្បាល នៅក្នុងស្ថានីយ៍ចិញ្ចឹមគោ ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៨ក្បាល គោបៅដោះចំនួន៣៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- បានចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន៦៥៨.២៩៧ក្បាល ជំងឺអុតក្តាមចំនួន១៦.៤០៦ក្បាល និងជំងឺបូសខ្យល់ចំនួន១.៩៨៧ក្បាល

- បានចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៦.០០៨ក្បាល ជំងឺប៉េស្តចំនួន១០.៨៦៧ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៥.៦៩៧ក្បាល ជំងឺអុតក្តាមចំនួន៤៦៥ក្បាល ជំងឺអូហេស្គីចំនួន១.៣៥៨ក្បាល ជំងឺរាគកូនជ្រូកចំនួន៣.៣៣៣ក្បាល ជំងឺកញ្ជ្រឹលចំនួន១៨៩ក្បាល ជំងឺជាតិដែកចំនួន១.៥៦៣ក្បាល និងជំងឺផ្លូវដង្ហើមចំនួន៣៣៤ក្បាល

- បានចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១៣.៤១៣ក្បាល ជំងឺញីវកាសចំនួន២០.៧៧០ក្បាល ជំងឺអាសន្នរោគចំនួន៤០.៣៩៦ក្បាល និងជំងឺប៉េស្តទាចំនួន២៣.៩៣៨ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យ

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក
- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ
- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត
- បានពិនិត្យវត្ថុវិភាគសរុបចំនួន៨៥សំណាក និងផ្នែកសរីរាគសាស្ត្រសរុបចំនួន២ក្បាល
- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន៣២៦ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំង

### ៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែង ឆាយរាប តំបន់ស្ទារក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

- តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសម្លេង(Radio Tracking)

-ប្រមូលគ្រាប់ពូជឈើកកោះនៅសហគមន៍ព្រៃឈើនាងកង្រី ខេត្តកំពង់ឆ្នាំង បានចំនួន៥០០គ.ក្រ និងយកមកបណ្តុះជាកូនឈើបានចំនួន២០.០០០ដើមសម្រាប់គម្រោងបុណ្យរុក្ខទិវា២០១៥

- ដាំឈើប្រភេទដូងចែមចំនួន០៥ហិកតាជាចម្ការពូជឈើនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

- បន្តស្រាវជ្រាវពូជឈើមានដោយកម្រនៅក្នុងតំបន់សហគមន៍ព្រៃឈើនានាសម្រាប់ទិសដៅប្រើប្រាស់គ្រាប់ពូជ។

### ៤.៦ ការងារដាំដើមឈើ

- ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ វិស័យឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានដាំឈើជាចម្ការបានចំនួន២០០ហិកតា។

### ៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើចំនួន៩៨៨ម៉³

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន១ ស្មើនឹង៥១សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន៧.១៧៣ម៉³។

### ៤.៨ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៣.១៩៦.៥៧២.១០០រៀល និងផ្តល់សេវាសាធារណៈចំនួន ១៧.៩៥៨,៥៦ដុល្លារ និង៦៣៤.១៩២.៦៤២រៀល។

### ៤.៩ ការងារនីតិកម្មនិងវិវាទ

- បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសចំនួន១០៨ករណី ដោយបញ្ជូនទៅតុលាការចំនួន៣៥ករណី និងពិន័យអន្តរការណ៍ចំនួន៧៣ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៥១ម៉³ ឈើអារចំនួន១៥៤ម៉³ ឈើក្រាក់គ្រញូងចំនួន០,៤៧០ម៉³និង៣.២០០គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន៤០គ.ក្រនិង៤០ក្បាល និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដកហូតរណារយន្តចំនួន៩៩គ្រឿង

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន ១១៩ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន៤៩ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ។

## ៥ វិស័យជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

ជាយថាភូតក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន២.០០០តោន ស្មើ១៣,៣៣% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន២៥.០០០តោន សរុបបានចំនួន២៤៥.០០០តោន ស្មើ៦២,៨២% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤០.០០០តោន

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាក្នុងខែចំនួន៤៩៥ច្បាប់ សរុបចំនួន៤.៤៧០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទក្នុងខែចំនួន៤៣០ច្បាប់ សរុបចំនួន៣.៧១៣ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១៤០ច្បាប់ សរុបចំនួន១.២៣០ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦២១ច្បាប់ សរុបចំនួន៦.៨២៧ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន១៤៣ច្បាប់ សរុបចំនួន៦២០ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៥០ច្បាប់ សរុបចំនួន៩៨០ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- រៀបចំលិខិតស្នើសុំសិទ្ធិប្រទាន ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី Cooperation in Agriculture and Related Fields រវាងកម្ពុជា-ស៊ីស្លែល

- រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបន្តអនុស្សរណៈរបស់អង្គការ Oxfam Australia

- សម្របសម្រួលរៀបចំបែបបទ និងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីរាជការក្រោមឱវាទដូចជាលិខិតឆ្លងដែន ពន្យារទិដ្ឋាការស្នាក់នៅ ព្រមទាំងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៧៧រូប នៅក្នុងប្រទេសចំនួន១៧។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦២៦នាក់ នារីចំនួន១.២៦៨នាក់ ស្មើនឹង១៩,១៥% រួមមាន៖

- អង្គភាពថ្នាក់កណ្តាលចំនួន៤.០៤៤នាក់ ក្នុងនោះនារីចំនួន៧៤២នាក់ ស្មើនឹង១៨,៣៤%
- អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៨២នាក់ ក្នុងនោះនារីចំនួន៥២៧នាក់ ស្មើនឹង២០,៤១%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខណ្ឌចំនួន៤៧នាក់ ក្នុងនោះបោះបង់ការងារចំនួន០១នាក់ និងមរណភាពចំនួន០៣នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៩៥នាក់
- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៨៧នាក់ និងក្នុងប្រទេសចំនួន០៣នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា
- បានរៀបចំការប្រឡងប្រជែងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១០ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥២៤នាក់(ស្រី៤៩៧នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រសរុបចំនួន១.៣១៣នាក់(ស្រី៤៣៩នាក់) និងថ្នាក់បរិញ្ញាបត្ររងសរុបចំនួន២១១នាក់(ស្រី៦០នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។

ក្នុងខែតុលា ឆ្នាំ២០១៤នេះមានជំងឺអុតក្តាមផ្ទុះលើសត្វគោ-ក្របីបន្តិចបន្តួច។ ទោះជាយ៉ាងណាមន្ត្រីជំនាញបានចុះពិនិត្យព្យាបាល និងតាមដានស្ថានភាពជំងឺសត្វយ៉ាងយកចិត្តទុកដាក់ ហើយក្រសួងក៏បានចាត់ក្រុមការងារចុះណែនាំ ជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្តឲ្យចុះដល់មូលដ្ឋានជាប្រចាំដើម្បីអន្តរាគមន៍តាមជាក់ស្តែងដូចជាការចាក់វ៉ាក់សាំង ការធ្វើអនាម័យ និងជីវសុវត្ថិភាពជាដើម។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងផលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងផលផលតាមគ្រប់រូបភាព។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

### ១.ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតដោយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផ្តល់កម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

- បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- ត្រៀមប្រជុំបូកសរុបការងារបង្កបង្កើនផលដំណាំស្រូវវស្សាឆ្នាំ២០១៤ នៅចុងឆ្នាំនេះ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឬត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- ធ្វើការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Insvitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះ។

### ២.ផ្នែកផលិតកម្មនិងបសុពេទ្យសាស្ត្រ :

- ចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការចិញ្ចឹមបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្ដែង

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្ដីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

- បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្ដីពីកៅស៊ូ ច្បាប់ស្ដីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្ដីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្ដីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤

(គិតត្រឹមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤)

| ល.រ | រាជធានី-ខេត្ត | ផែនការ | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហ.ត) | | | | | | សរុបស្ទូង និងព្រោះបុកដាំ (ហ.ត) | ភាគរយ (%) | ថ្ងៃខែឆ្នាំរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចម្ការ | ឡើងទឹក | | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | | |
| 01 | បន្ទាយមានជ័យ | 235,000 | 246,138 | 744 | 0.30 | 245,394 | 99.70 | 135 | 44,753 | 26,433 | 133,937 | 54,863 | - | 10,172 | 243,725 | 103.71 | បញ្ចប់ |
| 02 | បាត់ដំបង | 252,000 | 296,181 | 1,028 | 0.35 | 295,153 | 99.65 | 1,202 | 71,458 | 25,675 | 115,458 | 95,549 | 787 | 11,809 | 295,061 | 117.09 | បញ្ចប់ |
| 03 | កំពង់ចាម | 86,540 | 87,483 | 31,611 | 36.13 | 55,872 | 63.87 | 4,182 | 18,861 | 4,640 | 33,393 | 33,917 | - | 1,050 | 87,221 | 100.79 | បញ្ចប់ |
| 04 | កំពង់ឆ្នាំង | 109,500 | 191,570 | 73,037 | 38.13 | 118,533 | 61.87 | 18,295 | 7,279 | 1,407 | 90,581 | 23,282 | - | 511 | 121,653 | 111.10 | បញ្ចប់ |
| 05 | កំពង់ស្ពឺ | 113,600 | 170,179 | 92,903 | 54.59 | 77,276 | 45.41 | 13,394 | 21,706 | 1,773 | 64,284 | 14,546 | 375 | - | 100,911 | 88.83 | បញ្ចប់ |
| 06 | កំពង់ធំ | 210,000 | 214,671 | 86,952 | 40.50 | 127,719 | 59.50 | 6,613 | 30,289 | 7,033 | 100,920 | 63,132 | 4,704 | 14,036 | 213,081 | 101.47 | បញ្ចប់ |
| 07 | កំពត | 126,000 | 135,528 | 57,460 | 42.40 | 78,068 | 57.60 | 15,348 | 17,505 | 16,436 | 66,644 | 52,249 | - | - | 136,398 | 108.25 | បញ្ចប់ |
| 08 | កណ្តាល | 40,000 | 51,673 | 12,033 | 23.29 | 39,640 | 76.71 | 1,744 | 13,023 | 6,636 | 12,801 | 13,180 | 940 | 74 | 40,018 | 100.05 | បញ្ចប់ |
| 09 | កោះកុង | 10,400 | 9,171 | 2,219 | 24.20 | 6,952 | 75.80 | 859 | 2,363 | - | 5,694 | 1,100 | 1,244 | - | 10,401 | 100.01 | បញ្ចប់ |
| 10 | ក្រចេះ | 32,100 | 33,267 | 9,093 | 27.33 | 24,174 | 72.67 | 3,179 | 12,909 | 785 | 15,675 | 4,226 | 65 | - | 32,875 | 102.41 | បញ្ចប់ |
| 11 | មណ្ឌលគិរី | 20,000 | 24,300 | 1,160 | 4.77 | 23,140 | 95.23 | 3,816 | 3,922 | - | 10,795 | 4,675 | 3,631 | - | 23,023 | 115.12 | បញ្ចប់ |
| 12 | ភ្នំពេញ | 11,557 | 11,467 | 4,557 | 39.74 | 6,910 | 60.26 | 1,369 | 4,164 | - | 4,438 | 2,683 | - | - | 11,285 | 97.65 | បញ្ចប់ |
| 13 | ព្រះវិហារ | 75,570 | 75,439 | 6,768 | 8.97 | 68,671 | 91.03 | 3,349 | 11,300 | - | 43,369 | 18,619 | 3,280 | - | 76,568 | 101.32 | បញ្ចប់ |
| 14 | ព្រៃវែង | 250,000 | 272,532 | 43,258 | 15.87 | 229,274 | 84.13 | 1,771 | 90,891 | 21,090 | 146,853 | 34,685 | - | 103 | 272,532 | 109.01 | បញ្ចប់ |
| 15 | ពោធិ៍សាត់ | 100,000 | 115,141 | 18,297 | 15.89 | 96,844 | 84.11 | 6,424 | 47,856 | - | 32,423 | 22,146 | 2,112 | 6,569 | 111,106 | 111.11 | បញ្ចប់ |
| 16 | រតនគិរី | 26,500 | 14,329 | 4,614 | 32.20 | 9,715 | 67.80 | 1,419 | 3,652 | - | 5,144 | 5,392 | 11,737 | - | 25,925 | 97.83 | បញ្ចប់ |
| 17 | សៀមរាប | 180,000 | 232,480 | 73,320 | 31.54 | 159,160 | 68.46 | 10,110 | 39,060 | 1,230 | 87,970 | 42,055 | 6,735 | 8,215 | 184,035 | 102.24 | បញ្ចប់ |
| 18 | ព្រះសីហនុ | 16,500 | 16,510 | 4,953 | 30.00 | 11,557 | 70.00 | 621 | 1,695 | - | 10,017 | 4,855 | - | - | 16,567 | 100.41 | បញ្ចប់ |
| 19 | ស្ទឹងត្រែង | 27,400 | 25,183 | 9,173 | 36.43 | 16,010 | 63.57 | 2,341 | 13,956 | - | 9,913 | 1,314 | 2,668 | - | 27,851 | 101.65 | បញ្ចប់ |
| 20 | ស្វាយរៀង | 165,500 | 169,202 | 31,047 | 18.35 | 138,155 | 81.65 | 2,382 | 66,968 | 8,934 | 96,365 | 3,423 | - | - | 166,756 | 100.76 | បញ្ចប់ |
| 21 | តាកែវ | 170,000 | 408,470 | 130,915 | 32.05 | 277,555 | 67.95 | 6,931 | 106,702 | 51,198 | 85,494 | 7,409 | - | - | 199,605 | 117.41 | បញ្ចប់ |
| 22 | ឧត្តរមានជ័យ | 67,000 | 81,545 | 565 | 0.69 | 80,980 | 99.31 | 1,080 | 18,383 | - | 40,562 | 7,245 | 5,810 | - | 72,000 | 107.46 | បញ្ចប់ |
| 23 | កែប | 3,080 | 3,469 | 2,186 | 63.02 | 1,283 | 36.98 | 570 | 911 | | 2,184 | 374 | - | - | 3,469 | 112.63 | បញ្ចប់ |
| 24 | ប៉ៃលិន | 4,000 | 6,497 | - | | 6,497 | 100.0 | 45 | 1,428 | - | 4,774 | 295 | - | - | 6,497 | 162.43 | បញ្ចប់ |
| 25 | ត្បូងឃ្មុំ | 78,960 | 82,696 | 13,471 | 16.29 | 69,225 | 83.71 | 6,153 | 10,251 | 4,176 | 30,901 | 37,858 | - | - | 79,010 | 100.06 | បញ្ចប់ |
| សរុប | | **2,411,207** | **2,975,121** | **711,364** | **23.91** | **2,263,757** | **76.09** | **113,332** | **661,285** | **177,446** | **1,250,589** | **549,072** | **44,088** | **52,539** | **2,557,573** | **106.07** | |
| តួលេខសប្តាហ៍មុន | | **2,411,207** | **2,975,121** | **711,364** | **23.91** | **2,263,757** | **76.09** | **113,332** | **661,285** | **177,446** | **1,248,117** | **548,122** | **44,088** | **52,539** | **2,554,151** | **105.93** | |
| តួលេខឆ្នាំ២០១៣ | | **2,399,637** | **3,249,215** | **960,516** | **29.56** | **2,288,699** | **70.44** | **158,886** | **659,487** | **229,869** | **1,232,471** | **557,201** | **47,543** | **66,062** | **2,562,764** | **106.80** | |
| ប្រៀបធៀបឆ្នាំមុន | | **11,570** | **-274,094** | **-249,152** | **-5.65** | **-24,942** | **5.65** | **-45,554** | **1,798** | **-52,423** | **18,118** | **-8,129** | **-3,455** | **-13,523** | **-5,191** | **-0.73** | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤
ជ.ប្រធានការិយាល័យស្ថិតិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ**
**នាយកដ្ឋានផែនការនិងស្ថិតិ**

# ល្បឿនប្រមូលផលស្រូវវស្សាឆ្នាំ២០១៤

(គិតត្រឹមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | | ផ្ទៃដីប្រមូលផល | ទិន្នផល | បរិមាណផល | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រូវស្រាល | (ហត) | (តោន/ហ.ត) | (តោន) | (%) | |
| 01 | បន្ទាយមានជ័យ | 243,725 | 44,753 | 26,433 | 3.866 | 102,194 | 59.06 | 29-09-2014 |
| 02 | បាត់ដំបង | 295,061 | 71,458 | 51,803 | 2.200 | 113,967 | 72.49 | 28-10-2014 |
| 03 | កំពង់ចាម | 87,221 | 18,861 | 4,597 | 3.601 | 16,554 | 24.37 | 30-09-2014 |
| 04 | កំពង់ឆ្នាំង | 121,653 | 7,279 | 1,691 | 2.532 | 4,282 | 23.23 | 28-10-2014 |
| 05 | កំពង់ស្ពឺ | 100,911 | 21,706 | 1,739 | 3.177 | 5,524 | 8.01 | 26-08-2014 |
| 06 | កំពង់ធំ | 213,081 | 30,289 | 11,993 | 2.805 | 33,640 | 39.60 | 28-10-2014 |
| 07 | កំពត | 136,398 | 17,505 | 16,436 | 3.913 | 64,321 | 93.89 | 16-10-2014 |
| 08 | កណ្ដាល | 40,018 | 13,023 | 10,486 | 3.929 | 41,199 | 80.52 | 17-09-2014 |
| 09 | កោះកុង | 10,401 | 2,363 | 536 | 2.543 | 1,363 | 22.68 | 28-10-2014 |
| 10 | ក្រចេះ | 32,875 | 12,909 | 785 | 2.850 | 2,237 | 6.08 | 08-08-2014 |
| 11 | មណ្ឌលគិរី | 23,023 | 3,922 | 71 | 2.704 | 192 | 1.81 | 16-09-2014 |
| 12 | ភ្នំពេញ | 11,285 | 4,164 | 227 | 2.802 | 636 | 5.45 | 07-10-2014 |
| 13 | ព្រះវិហារ | 76,568 | 11,300 | | - | | - | |
| 14 | ព្រៃវែង | 272,532 | 90,891 | 50,826 | 3.570 | 181,427 | 55.92 | 14-10-2014 |
| 15 | ពោធិ៍សាត់ | 111,106 | 47,856 | 20,804 | 3.403 | 70,800 | 43.47 | 28-10-2014 |
| 16 | រតនគិរី | 25,925 | 3,652 | | - | | - | |
| 17 | សៀមរាប | 184,035 | 39,060 | 12,410 | 2.340 | 29,039 | 31.77 | 28-10-2014 |
| 18 | ព្រះសីហនុ | 16,567 | 1,695 | | - | | - | |
| 19 | ស្ទឹងត្រែង | 27,851 | 13,956 | 3,257 | 2.700 | 8,793 | 23.34 | 21-10-2014 |
| 20 | ស្វាយរៀង | 166,756 | 66,968 | 19,513 | 3.200 | 62,441 | 29.14 | 28-10-2014 |
| 21 | តាកែវ | 199,605 | 106,702 | 51,198 | 4.221 | 216,107 | 47.98 | 25-09-2014 |
| 22 | ឧត្ដរមានជ័យ | 72,000 | 18,383 | | - | | - | |
| 23 | កែប | 3,469 | 911 | 336 | 3.899 | 1,310 | 36.88 | 10-09-2014 |
| 24 | ប៉ៃលិន | 6,497 | 1,428 | | - | | - | |
| 25 | ត្បូងឃ្មុំ | 79,010 | 10,251 | 5,495 | 3.330 | 18,298 | 53.60 | 28-10-2014 |
| សរុប | | **2,557,573** | **661,285** | **290,636** | **3.352** | **974,324** | **43.95** | |
| តួលេខសប្ដាហ៍មុន | | **2,552,436** | **661,094** | **254,510** | **3.321** | **845,167** | **38.50** | |
| តួលេខឆ្នាំ២០១៣ | | **2,562,764** | **659,487** | **253,641** | **3.674** | **915,227** | **38.46** | |
| ប្រៀបធៀបឆ្នាំមុន | | **-5,191** | **1,798** | **36,995** | **-0.322** | **59,097** | **5.490** | |

**បានឃើញនិងឯកភាព**
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤
ជ. ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

## ស្ថានភាពផ្ទៃដីប៉ះពាល់និងខូចខាតស្រូវរដូវវស្សាឆ្នាំ ២០១៤

(គិតត្រឹមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤)

| រាជធានី ខេត្ត | ផ្ទៃដី អនុវត្ត (ហ.ត) | ប៉ះពាល់ (ហ.ត) | | | | | | សរុប ប៉ះពាល់ (ហ.ត) | | ខូចខាត (ហ.ត) | | | | | | សរុប ខូចខាត (ហ.ត) | | ផ្ទៃដីស្តារ ឡើងវិញ (ហ.ត) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | | | កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | | | | |
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| បន្ទាយមានជ័យ | 243,725 | | | | | | | - | - | | | | | | | - | - | | |
| បាត់ដំបង | 295,061 | - | 39,848 | | | - | 1,080 | - | 40,928 | - | 8,639 | | | - | 930 | - | 9,569 | - | 2,332 |
| កំពង់ចាម | 87,221 | | | | | 23 | 7,402 | 23 | 7,402 | | | | | 23 | 2,697 | 23 | 2,697 | - | 2,116 |
| កំពង់ឆ្នាំង | 121,653 | | | | | - | 353 | - | 353 | | | | | - | 263 | - | 263 | - | - |
| កំពង់ស្ពឺ | 100,911 | 5,966 | 4,399 | | | | | 5,966 | 4,399 | 1,671 | 290 | | | | | 1,671 | 290 | - | - |
| កំពង់ធំ | 213,081 | | | | | - | 9,690 | - | 9,690 | | | | | - | 2,465 | - | 2,465 | - | 424 |
| កំពត | 136,398 | | | | | | | - | - | | | | | | | - | - | | |
| កណ្តាល | 40,018 | 535 | 805 | | | - | 3,566 | 535 | 4,371 | 18 | 62 | | | - | 818 | 18 | 880 | - | - |
| កោះកុង | 10,401 | | | | | | | - | - | | | | | | | - | - | | |
| ក្រចេះ | 32,875 | | | | | 49 | 6,839 | 49 | 6,839 | | | | | 44 | 3,772 | 44 | 3,772 | - | 2,123 |
| មណ្ឌលគិរី | 23,023 | | | | | 150 | 1,100 | 150 | 1,100 | | | | | - | 465 | - | 465 | - | 172 |
| ភ្នំពេញ | 11,285 | 227 | 627 | | | | | 227 | 627 | 6 | 3 | | | | | 6 | 3 | | - |
| ព្រះវិហារ | 76,568 | | | | | - | 6,741 | - | 6,741 | | | | | - | 2,784 | - | 2,784 | - | - |
| ព្រៃវែង | 272,532 | 10 | 8,022 | | | - | 30,496 | 10 | 38,518 | - | 532 | | | - | 5,199 | - | 5,731 | - | 532 |
| ពោធិ៍សាត់ | 111,106 | - | 7,026 | | | - | 79 | - | 7,105 | - | 3,029 | | | - | 79 | - | 3,108 | - | - |
| រតនគិរី | 25,925 | | | | | | | - | - | | | | | | | - | - | | |
| សៀមរាប | 184,035 | | | | | - | 1,010 | - | 1,010 | | | | | - | 40 | - | 40 | - | - |
| ព្រះសីហនុ | 16,567 | | | | | | | - | - | | | | | | | - | - | | |
| ស្ទឹងត្រែង | 27,851 | | | | | - | 4,471 | - | 4,471 | | | | | - | 2,604 | - | 2,604 | - | 1,637 |
| ស្វាយរៀង | 166,756 | - | 10,104 | | | - | 2,403 | - | 12,507 | - | 4,205 | | | - | 152 | - | 4,357 | - | 4,252 |
| តាកែវ | 199,605 | 918 | 30,952 | | | - | 139 | 918 | 31,091 | 217 | 939 | | | - | - | 217 | 939 | 217 | 939 |
| ឧត្តរមានជ័យ | 72,000 | - | 5,036 | | | - | 165 | - | 5,201 | - | 475 | | | - | - | - | 475 | - | - |
| កែប | 3,469 | | | | | | | - | - | | | | | | | - | - | | |
| ប៉ៃលិន | 6,497 | | | | | | | - | - | | | | | | | - | - | | |
| ត្បូងឃ្មុំ | 79,010 | | | | | 28 | 2,544 | 28 | 2,544 | | | | | 26 | 1,072 | 26 | 1,072 | - | - |
| សរុប | 2,557,573 | 7,656 | 106,819 | - | - | 250 | 78,078 | 7,906 | 184,897 | 1,912 | 18,174 | - | - | 93 | 23,340 | 2,005 | 41,514 | 217 | 14,527 |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤
ជ. ប្រធានការិយាល័យស្ថិតិ